# កំណត់ហេតុ

## វេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី ២៥

## **របៀបប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (E-Filing)**

*ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០២០*

*ម៉ោង ៩ :៣០ ដល់ ១១:៣០ ព្រឹក*

*តាមរយៈប្រព័ន្ធអនឡាញ **Google Meet***



## មាតិកា


១. សេចក្តីផ្តើម ........ 3

២. ដំណើរការ និងលទ្ធផល ........ 3

២.១ មតិស្វាគមន៍ និងបើកម្មវិធី ........ 3

២.២ បទបង្ហាញពីបច្ចុប្បន្នភាពព័ត៌មានស្តីពីច្បាប់ពន្ធដារ និងបទបញ្ញាតិនានាពាក់ព័ន្ធនឹងវិស័យពន្ធដារ ........ 4

២.៣ បទបង្ហាញពីការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (E-Filing) ........ 8

៣. វេទិកាពិភាក្សា សំណួរ និងចម្លើយ ........ 9

៤. បិទកម្មវិធី ........ 16

៥. លទ្ធផលវាយតម្លៃវគ្គសិក្សារៀនសូត្រ ........ 16

៥.១.ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ ........ 16

៦. ឧបសម្ព័ន្ធ ........ 18





www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

## ១. សេចក្ដីផ្ដើម

ដើម្បីឆ្លើយតបនឹងតម្រូវការខាងសមត្ថភាពបច្ចេទេសរបស់សមាគមអង្គការមិនមែនរដ្ឋាភិបាល និងដើម្បីចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ១៩ តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្ដីណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) សហការជាមួយសមាជិកនៃក្រុមការងារចម្រុះផ្នែកពន្ធដារ នឹងរៀបចំវេទិការៀនសូត្រស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី ២៥ ពីចំងាយតាមប្រព័ន្ធអនឡាញ (Google Meet) ក្រោមប្រធានបទ **"របៀបប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (E-Filing)"** ។

ត្រឹមខែធ្នូ ឆ្នាំ២០១៩ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) មានសមាជិកសរុបទាំងអស់ចំនួន ២០៨ ស្ថាប័ន ទាំងអង្គការ/សមាគមក្នុងស្រុក និងអង្គការ/សមាគមបរទេស ព្រមទាំងមានដៃគូជាបណ្ដាញអង្គការសមាគមមិនមែនរដ្ឋាភិបាលជាច្រើនទៀត ក្នុងខេត្តចំនួន១៥ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុត សម្រាប់ អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

អ្នកចូលរួម នឹងមានការយល់ដឹងនិងការសម្រេចចិត្តកាន់តែច្បាស់លាស់ ទៅលើល័ក្ខខ័ណ្ឌការងារ (ប្រភេទកិច្ចសន្យាការងារ អត្ថប្រយោជន៍នៃការបញ្ចប់កិច្ចសន្យា និងការបើកប្រាក់បំណាច់អតីតភាព...) សម្រាប់បុគ្គលិកក្នុងអង្គការរបស់អ្នក។

## ២. ដំណើរការ និងលទ្ធផល

វេទិការៀនសូត្រនេះធ្វើឡើងតាមរយៈអនឡាន ដែលមានអ្នកចូលរួមចំនួន ២២៣នាក់ ដែល ៦៥%(១៤៥នាក់)ជាស្ត្រី មកពីអង្គការក្នុងស្រុក និងអង្គការបរទេស ដែលជាសមាជិក មិនមែនជាសមាជិកអង្គការ គសក និងបណ្ដាញអង្គការតាមខេត្ត។

### ២.១ មតិស្វាគមន៍ និងបើកម្មវិធី

ជាកិច្ចចាប់ផ្ដើម **លោក សឿង សារឿន** ជានាយកប្រតិបត្តិនៃ អង្គការ គ.ស.ក បានសម្ដែងនូវសេចក្ដីសោមនស្សរីករាយជាខ្លាំង ដោយសង្ឃឹមថា លោក-លោកស្រី អ្នកនាងកញ្ញាមានសេចក្ដីសុខសុភមង្គល ទោះបីស្ថិតក្នុងស្ថានភាពនៃការរីករាតត្បាតនៃមេរោគ កូវីត១៩យ៉ាងណាក្ដី ។ លោកពិតជាអរ

គុណដល់ ក្រុមការងាររបស់អង្គការគ.ស.កទាំងអស់ ក្រុមការងារពីនាយកដ្ឋានពន្ធដារក្រោមការដឹកនាំពីគណៈប្រតិភូនៃរាជរដ្ឋាភិបាល ឯកឧត្តម គង់ វិបុល ដែលមានសហការីជាវាគ្មិនកិត្តិយសចំនួនបីរូប ដែលមានលោក **ប៉ូ ពិសិដ្ឋ** លោក **ស្រេង រតនា** និងលោក **យឿង វិសាល**។ ហើយក៏អរគុណច្រើនណាស់ដែលលោកទាំងបីបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចែករំលែកបទពិសោធចំណេះដឹង ដល់ក្រុមការងារផ្នែកហិរញ្ញវត្ថុសមាជិកសមាជិកានៃអង្គការ គ.ស.ក ជាពិសេសសមាសភាគអ្នកចូលរួមទាំងអស់ក្នុងថ្ងៃនេះ ក្នុងការចូលរួមសិក្សារៀនសូត្រស្តីពីការប្រកាសពន្ធ អំពី របៀបរៀបចំ ឯកសារ តាមរយៈប្រព័ន្ធអនឡាញ។ នេះគឺជាការរៀបចំថ្មី និងពិភាក្សាមួយរវាងអង្គការសង្គមស៊ីវិល និងស្ថាប័នរបស់រដ្ឋាភិបាល ពីការរៀនសូត្រជាមួយគ្នានៃការអនុវត្ត ច្បាប់ពន្ធដារកន្លងមក។ លោក នៅតែមានជំនឿទុកចិត្តថាការចូលរួមតាមអនឡាញជាឱកាសដ៏សំខាន់ និងមានតម្លៃ នូវការបន្តកសាងមិត្តភាព និងបណ្តាញកាន់តែប្រសើរ និងរៀនសូត្រពីអ្វីថ្មីពីច្បាប់ពន្ធដារ។ បើសិនជាអ្នកចូលរួមមាន ជាបញ្ហាប្រឈមណាមួយក្នុងអង្គភាពរបស់ខ្លួនអាច លើកឡើងនិង ជជែកផ្ទាល់ ក្នុងការឆ្លើយតប ដោយចំហដោយតម្លាភាព និងភាពស្មោះត្រង់ដើម្បីជាប្រយោជន៍ដល់អង្គការសង្គមស៊ីវិលផងនិងដល់ប្រទេសជាតិផង។ ជាថ្មីម្តងទៀតអរគុណដល់ក្រុមការងាររៀបចំសិក្សាវេទិកា ហិរញ្ញវត្ថុ ខាងពន្ធដារ សមាជិកសមាជិកាចូលរួមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច៕

## ២.២ បទបង្ហាញពីបច្ចុប្បន្នភាពព័ត៌មានស្តីពីច្បាប់ពន្ធដារ និងបទបញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យពន្ធដារ

**លោកប៉ូ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យមនៃអគ្គនាយកដ្ឋានពន្ធដារ លោកបានបញ្ជាក់ថានាព្រឹកនេះ អ្នកតំណាងនៃនាយកដ្ឋានពន្ធដារមានបទបង្ហាញចំនួនបី ដើម្បីចែករំលែកទៅដល់សមាជិក អង្គការគ.ស.កដែលបានចូលរួមនៅក្នុងវេទិកា ក៏ដូចជាវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធអនឡាញ។បទបង្ហាញទាំងបីនោះរួមមាន៖

ទី១. ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយខ្សែរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ធ្វើបទបង្ហាញផ្ទាល់ដោយលោក **ប៉ូ ពិសិដ្ឋ**

ទី២. កាតព្វកិច្ចសារពើរពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល នឹងធ្វើបទបង្ហាញដោយលោក **យឿង វិសាល** និង

ទី៣. ទាក់ទងនឹង E-Filing ការប្រកាសពន្ធតាមប្រព័ន្ធអនឡាញធ្វើបទបង្ហាញដោយ **លោក ស្រេង រតនា**។

**ការចុះបញ្ជីអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលៈ** លើមាតិកាចំនួន បី គឺ

**ទី១.** ច្បាប់ និងបទប្បញ្ញាតិស្តីពីពន្ធដាទាក់ទៅនឹងការចុះបញ្ជី

**ទី២.** ការចុះបញ្ជីនៅពន្ធដារ និង

**ទី៣.** កាតព្វកិច្ចស្តីពីការកាន់កាប់បញ្ជិកាគណនេយ្យ។

**ទី១. ច្បាប់ និងបទប្បញ្ញាតិស្តីពីពន្ធដារទាក់ទៅនឹងការចុះបញ្ជីៈ**

- យោងតាមមាត្រា១០១ នៃច្បាប់សារពើពន្ធ ដោយមានចែងលើកឡើងថា **"បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង១៥ ថ្ងៃក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច"**។ នេះមានន័យ អង្គការសង្គមស៊ីវិលដែលមានសកម្មភាពសេដ្ឋកិច្ច គឺតម្រូវឱ្យមកធ្វើការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរយៈពេល១៥ថ្ងៃ ក្រោយពេលដែលគាត់មានសកម្មភាពសេដ្ឋកិច្ច ការធ្វើបច្ចុប្បន្នភាព នៃអាជីវកម្ម សមាភាគអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការងារពន្ធដាររបស់សហគ្រាស។
- លោកទទូចស្នើសុំ និងសហការជាមួយអង្គការសង្គមស៊ីវិល ក៏ដូចជាដៃពាក់ព័ន្ធផ្សេងទៀតក្នុងការផ្តល់នូវពត៌មានចាំបាច់ទាក់ទងបច្ចុប្បន្នភាពនេះ ពិសេសការចែករំលែកពត៌មាន បទប្បញ្ញាតិដូចជាការផ្លាស់ប្តូរនូវទីតាំង អង្គភាព គណៈគ្រប់គ្រង ឬនាយកប្រតិបត្តិ។
- ថ្មីៗនេះអគ្គនាយកដ្ឋានពន្ធដារស្តីពីការចុះបញ្ជីអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយដែលអាជីវកម្មដោយឡែកមិនស្ថិតនៅក្នុងគោលដៅសុទ្ធសាធរបស់ខ្លួនត្រូវចុះបញ្ជីដោយឡែកមួយទៀតនៅរដ្ឋបាលសារពើពន្ធនៅក្នុងរយៈពេល១៥ថ្ងៃគឺមានសកម្មភាពអាជីវកម្មនឹងត្រូវចាត់ទុកថាជាសហគ្រាសឯកបុគ្គល។
- ប្រកាសលេខ ០២៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសៈ

- **អ្នកជាប់ពន្ធតូច** មានផលរបរប្រចាំឆ្នាំ ចាប់ពី ២៥០លាន ដល់ ៧០០លានរៀល


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

- **អ្នកជាប់ពន្ធមធ្យម** សហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី ៧០០ លានរៀល ដល់៤០០០ លានរៀល
- **អ្នកជាប់ពន្ធធំ** ទៅគឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៤ ០០០លានរៀល ឡើងទៅ

➢ *មាត្រា ១០៣ នៃច្បាប់ស្តីពីសារពើពន្ធ*

"រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី"

➢ *មាត្រា ១២៨ និង មាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ*

➢ ការខកខានមិនបានមកចុះបញ្ជីពន្ធដារតាមកាលកំណត់ត្រូវបានចាត់ទុកថាបានប្រព្រឹត្តិអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលនឹងត្រូវទទួលរងនូវការផាកពិន័យ ឱ្យបង់ពន្ធបន្ថែមចំពោះការប្រព្រឹត្តិអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារជាប្រាក់ចំនួន ២លានរៀលគត់។

➢ យោងទៅតាមមាត្រាទី១៣៦ នៃច្បាប់ស្តីពីសារពើរពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតដល់ទោសទណ្ឌផ្សេងៗទៀត បុគ្គលទាំងឡាយដែលបានប្រព្រឹត្តិនូវអំពើរាំងស្ទះបទប្បញ្ញាតិស្តីពីពន្ធដារដូចមានចែងនៅក្នុងមាត្រាទី១២៨នៃច្បាប់សារពើរពន្ធត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៥លានទៅដល់១០ លាន ឬជាប់ពន្ធធនាគារពី ១ខែដល់ ១ឆ្នាំ ឬទោសទាំងពីរ។

➢ ដើម្បីអាចធ្វើការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយឡែកត្រូវភ្ជាប់មកនូវជាមួយនូវសំណុំឯកសារមួយចំនួន ច្បាប់ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ឯកសារទាំងនោះរួមមាន ៖ ទី១.ទម្រង់ពាក្យស្នើសុំ S01 របស់អង្គការសង្គមស៊ីវិលជាអ្នកជាប់ពន្ធតូច និងអ្នកជាប់ ពន្ធមធ្យម ឬធំបំពេញទម្រង់១០១ ព្រមទាំងឯកសារមួយចំនួនដូចជា ទី២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនមានសុពលភាព សៀវភៅធនាគារ ទី៣. រូបថតបច្ចុប្បន្នមិនលើសពី៣ខែ ៣៥ទំហំ )x៤៥ (ប័ណ្ណកាន់កាប់សន្យាជួលទីតាំងប្រកបអាជីវកម្ម។ *ចំពោះខ្លឹមសារលម្អិតបន្ថែម សូមចូលទៅបើកមើលក្នុងតំណភ្ជាប់នៃស្លាយខាងក្រោម*



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia




**លោក យឿង វិសាល** អនុប្រធានការិយាល័យអ្នកជាប់ពន្ធតូច និងមធ្យមៈ លោកសម្តែងនូវការគោរពចំពោះអនុប្រធាននាយកដ្ឋានពន្ធដារ និងក្រុមការងារ សមាសភាគសមាជិក អង្គការសង្គមស៊ីវិលទាំងអស់ ក្នុងកម្មវិធីតាមអនឡាញថ្ងៃនេះ ដែលលោកមានកិត្តិយល់ផ្តល់ជាបទបង្ហាញ**ស្តីពីប្រកាសណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។** ជាទិដ្ឋភាពទូទៅ ក្នុងនោះមានគោលបំណង ការពង្រឹងការអនុវត្តសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ គោលដៅដើម្បីផ្តល់ការណែនាំនៃច្បាប់សារពើពន្ធប្រកបដោយ ប្រសិទ្ធិភាពនិងស័ក្តិសិទ្ធភាព។

- លោកបានផ្តល់ជានិយមន័យ របស់ សមាគម អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក ឬអង្គការអន្តរជាតិ ។
- ការលើកលែងពន្ធលើប្រាក់ចំណូល ដូចជា សកម្មភាពគោលដៅសុទ្ធសាធ សំដៅដល់ដំណើកាសម្រាប់ គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រអប់រំ ហើយគ្មានចំណែកណាមួយជាទ្រព្យប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។
- សកម្មភាពមិនស្ថិតគោលដៅសុទ្ធសាធ សំដៅដល់សកម្មភាពអាជីវកម្មដោយឡែកដើម្បីស្វែងរកប្រាក់ចំណេញ ឬមូលនិធិ ក្រៅពីសកម្មភាពគោលដៅសុទ្ធសាធ។

**ការលើកលែងព័ន្ធលើប្រាក់ចំណូលៈ**

- ដាក់ពាក្យស្នើសុំលើកលែងពន្ធលើប្រាក់ចំណូលមកអគ្គនាយកដ្ឋាន រួមមានឯកសារភ្ជាប់

១. លក្ខន្តិកៈ និងលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃ (អង្គការ សមាគមក្នុងស្រុក)

២. អនុស្សារណៈជាមួយក្រសួងការបរទេសននិងសហប្រតិបត្តិការអន្តរជាតិ

៣. ត្រូវជូនដំណឹងមកអគ្គនាយកដ្ឋានពន្ធដាររាល់ការផ្លាស់ប្តូរនានា


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

*ចំពោះខ្លឹមសារលម្អិតបន្ថែម សូមចូលទៅបើកមើលក្នុងតំណភ្ជាប់នៃស្លាយខាងក្រោម*




## ២.៣ បទបង្ហាញពីការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ ( E-Filing )

**លោក ស្រេង រតនា** អនុប្រធានករិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារះ ជាបឋមលោក សូមគោរពប្រធាននាយកដ្ឋាន អស់លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងវេទិកានាព្រឹកនេះ។ លោកពិតជាមានសេចក្តីរីករាយជាខ្លាំងដែលបានធ្វើបទបង្ហាញ សង្ខេប និងលម្អិតត្រង់ចំណុចសំខាន់ៗដើម្បីឱ្យរាល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធិភាព។

- សិក្សាពីមុខងារសំខាន់ៗមួយចំនួន ពាក់ព័ន្ធពីការបង្កើតគណនីនៅក្នុង E-Filing
- គណនីរបស់អ្នកប្រើប្រាស់ តាមប្រព័ន្ធ E-VATអាចយកមកប្រើជាមួយប្រព័ន្ធ E-Filing បានគ្រាន់ថា ប្រព័ន្ធ E-Filing យកឈ្មោះអ្នកប្រើប្រាស់ ដោយយកអ៊ីម៉ែលជាគោល(Username)
- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ នឹងទទួលបាននូវ លេខ VATIN លេខកាតសម្គាល់ការចុះបញ្ជីពន្ធដារ និងលេខ ទូរកស័ព្ទអ្នកឈរលើប៉ាតង់ ក្នុងប្រព័ន្ធ E-Filing
- ចំណុចដែលសំខាន់ដែលប្រព័ន្ធ E-Filing ធ្វើឡើងប្រសិនជាអ្នកប្រើប្រាស់អនុវត្តនូវមុខងារទាំងអស់ រួមមាន (១)បញ្ជីទិញ-លក់ ការប្រកាសពន្ធប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ការបោះពុម្ពពាក្យស្នើសុំបង់ និងប្រកាសពន្ធតាមប្រព័ន្ធអនឡាញ។

*ចំពោះខ្លឹមសារលម្អិតបន្ថែម សូមចូលទៅបើកមើលក្នុងតំណភ្ជាប់នៃស្លាយខាងក្រោម*



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia







*ចំពោះខ្លឹមសារលម្អិតបន្ថែម សូមចូលទៅកាន់តំណភ្ជាប់នៃស្លាយខាងក្រោម៖*

https://www.ccc-cambodia.org/en/resources/event-archives/virtual-finance-learning-forum

## ៣. វេទិកាពិភាក្សា សំណួរ និងចម្លើយ

សម្របសម្រួលដោយលោក **យឿង សុធារ៉ា** ប្រធានផ្នែកកសាងភាពជាដៃគូ បណ្តាញ និងការតស៊ូមតិ នៃអង្គការ គសក៖ លោកបានបានដកស្រង់សំណួរដែលអ្នកចូលរួមបានសួរ ក្នុងប្រអប់សារ គោរពអញ្ជើញអ្នកចូលរួមទាំងអស់បានសរសេរជាសំណួរបន្ថែមទៀតនៅក្នុងប្រអប់សារ ហើយលោកក៏



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

បានណែនាំពីវាគ្មិនកិត្តិយសនៃអគ្គនាយកដ្ឋានពន្ធដារក្នុងការត្រៀមលក្ខណៈរួចរាល់ដើម្បីឆ្លើយតបសំណួរចម្លើយពីសំណាក់អ្នកចូលរួមក្នុងវេទិកាថ្ងៃនេះ ដែលពាក់ព័ន្ធច្បាប់ លិខិតបទដ្ឋាននិងអនុលោមភាពនៃច្បាប់ ស្តីពច្បាប់ពន្ធដារទាំងអស់។

**សំណួរទី១**: តើការបង់ពន្ធ E-Filing ត្រូវគិតពីសាខាពន្ធដារឬទេ? បើយើងមិនចង់ធ្វើតាម E-Filing តើយើងអាចបំពេញទម្រង់នេះជា Hard Copy បានដែរឬទេ?

**ចម្លើយទី១៖** ចំពោះអស់លោក លោកស្រីធ្វើ E-Filing នូវមុខងារទាំងបី មានបញ្ជីទិញលក់ (E-VAT) ពន្ធកាត់ទុក (WHT) និងប្រាក់បៀវត្សរ៍ (ToS) ព្រមទាំងអត្ថប្រយោជន៍បន្ថែម (FB)។បន្ថិចទៀត GDT នឹងមានចេញប្រព័ន្ធ E-Payment ដែលលោកអ្នក អាចបង់ពន្ធតាមអនទ្បាញតែម្តង ដូច្នេះលោក-លោកស្រី មិនចាំបាច់អញ្ជើញមករដ្ឋបាលសារពើពន្ធដែលទទួលបន្ទុកបង់ពន្ធដើម្បីដាក់ឯកសារ (Hard Document) នោះទេ ពីព្រោះលោក-លោកស្រី បានប្រកាសពន្ធ និងបង់ពន្ធតាមប្រពន្ធអនទ្បាញរួចហើយ។

ដោយឡែកប្រព័ន្ធ E-Payment មិនទាន់ដាក់ឱ្យប្រើប្រាស់នៅឡើយទេ ដូច្នេះ ជាជម្រើស លោកអ្នកអាចបង់ប្រាក់ពន្ធនៅតាមធនាគារ នៅពេល លោក-លោកស្រីបង់ពន្ធនៅតាមធនាគារ លោក-លោកស្រីនឹងទទួលបាន វិក្ក័យបត្រពីរសន្លឹក ពណ៌សមួយសន្លឹក និងពណ៌ផ្កាឈូកមួយសន្លឹក (Single Invoice) ឬហៅថាលិខិតបញ្ជាក់បង់ប្រាក់ពន្ធ។ បន្ទាប់មកសូមយកវិក្ក័យបត្រនោះទៅសាខាពន្ធដារ បង្កាន់ដៃពណ៌ផ្កាឈូកប្រគល់ឱ្យអ្នកបង់ពន្ធ រីឯបង្កាន់ដៃពណ៌ស ខាងសាខាពន្ធនិង រក្សាទុក។ រីឯលិខិតប្រកាសមិនបាច់បំពេញដោយដៃទៀតទេ។

**សំណួរទី២**: តើនៅក្នុង E-filing សម្រាប់ព័ត៌មានរូបវន្តបុគ្គលទាំងអស់អាចយកទិន្នន័យ data(sync) ពីអគ្គនា យកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃបានឬទេ? ដើម្បីងាយស្រួល និងសន្សំពេលវេលាពេលយើង កត់ត្រាចំណាយណាដែលផ្គត់ផ្គង់ដោយបុគ្គលរូបវន្តបុគ្គលទាំងនោះដោយគ្រាន់តែវាយលេខអត្តសញ្ញាណប័ណ្ណ ទិន្នន័យទាំងអស់នឹងផ្ទេរទិន្នន័យមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានពន្ធដារ។

**ចម្លើយទី២៖** នៅក្នុងដំណាក់កាលអន្តរការណ៍នេះការផ្ទេរព័ត៌មានពីស្ថាប័នមួយទៅស្ថាប័នមួយសម្រាប់រដ្ឋាភិបាលគឺយើងនៅមានកម្រិតនៅឡើយ ប៉ុន្តែរដ្ឋាភិបាលកំពុងតែបង្កើតនូវ Big data ស្ថាប័ន

ដែលមាន dataធំជាទិន្នន័យធំ សម្រាប់ការចុះបញ្ជីមួយកន្លែងហើយអាចចែករំលែកបានគ្រប់ស្ថាប័នពាក់ព័ន្ធ។ ហេតុនេះនៅក្នុងពេលបច្ចុប្បន្នគឺតម្រូវឱ្យចុះទាំងពីរស្ថាប័ន។

**សំណួរទី៣**: ប្រសិនបើអង្គការ សមាគមមានចំណូលពីសកម្មភាពអាជីវកម្មដាច់ដោយឡែកតិចជាង២៥០លានរៀល ចាំបាច់ត្រូវចុះបញ្ជីពន្ធដារដែរ?

**ចម្លើយទី៣៖** អង្គការ សមាគមមានចំណូលពីសកម្មភាពអាជីវកម្មដាច់ដោយឡែកតិចជាង២៥០លានរៀល ចាំបាច់ត្រូវចុះបញ្ជី ប៉ុន្តែមិនចាំបាច់ប្រកាសពន្ធទេ។

**សំណួរទី៤**: អង្គការអន្តរជាតិ/អង្គការបរទេស ដែលមានអនុស្សារណៈជាមួយក្រសួងការបរទេស គួរដាក់ពាក្យស្នើសុំលើកលែងពន្ធលើប្រាក់ចំណូលរឺទេ?

**ចម្លើយទី៤៖** បើសិនជាគាត់មិនមែនជាអង្គការអន្តរជាតិដែលទទួលស្គាល់ដោយរដ្ឋាភិបាល ពីប្រទេសច្រើននោះទេ ពួកគាត់គួរតែដាក់លិខិតមកពន្ធដារដើម្បីសុំការលើកលែងពន្ធប្រាក់ចំណូល។ អង្គការសមាគមបរទេស សំដៅលើអង្គភាពណាដែលគាត់ចុះបញ្ជីនៅបរទេសហើយមកធ្វើប្រតិបត្តិការនៅកម្ពុជាដោយមានការទទួលស្គាល់ពីរដ្ឋាភិបាលឬអាជ្ញាធរកម្ពុជាផ្តល់មូលនិធិ ឬជំនួយមនុស្សធម៌ផ្សេងៗ។ ដូច្នេះពួកគាត់ជាអង្គការ សមាគមបរទេសដែលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីអង្គការសមាគម ដូច្នេះពួកគាត់ត្រូវដាក់ពាក្យ ស្នើសុំលើកលែងពន្ធប្រាក់ចំណូល។

**សំណួរទី៥**: តើការដាក់ពាក្យស្នើរសុំលើកលែងពន្ធលើប្រាក់ចំណូល យើងត្រូវធ្វើតែម្តង រឺត្រូវធ្វើជារៀងរាល់ឆ្នាំ?

**ចម្លើយទី៥៖** យោងតាមការស្នើសុំនេះ បើយោងទៅតាមសេចក្តីណែនាំ បើសិនជាអង្គការសមាគម បានធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួនដែលបានដំកល់ជាមួយនឹងក្រសួងពាក់ព័ន្ធ គឺតម្រូវឱ្យធ្វើការស្នើសុំសារថ្មី។

**សំណួរទី៦**: តើការដាក់លិខិតស្នើរសុំការលើកលែងពន្ធលើប្រាក់ចំណូលត្រូវធ្វើឡើងរឺទេចំពោះប្រាក់ចំណូលមូលនិធិ? បើដាក់តើដាក់នៅសាខាខេត្ត ឬនៅអគ្គនាយកដ្ឋានពន្ធដារ? តើត្រូវដាក់រាល់ឆ្នាំ រឺតែម្តង?



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

**ចម្លើយទី៦៖** អាចដាក់ពាក្យស្នើសុំតាមសាខាពន្ធដារ តាមខេត្ត-ខណ្ឌបាន សាខាពន្ធដារខេត្ត ខណ្ឌនឹងផ្ញើរមកអគ្គនាយកដ្ឋានពន្ធដារ ប៉ុន្តែក្នុងករណីដែលអង្គការសមាគមមានទីតាំងនៅរាជធានី ភ្នំពេញ អាចដាក់មកត្រង់តែម្តងនៃអគ្គនាយកដ្ឋានពន្ធដារ។អាចមានជម្រើសពីរ គាត់អាចដាក់តាម សាខាពន្ធដារ ខេត្ត-ខណ្ឌក៏បានឬក៏មកអគ្គនាយក ដ្ឋានពន្ធដារ។

**សំណួរទី៦**: តើអាចបំពេញទម្រង់លើក្រដាស/ the paper form បានទេ ក្នុងករណីមិនទាន់ចេះ ប្រើ e-filing?

**ចម្លើយទី៦៖** ពាក់ព័ន្ធទៅនឹងមុខងារ E-filing មែនទែនទៅវាជាការ update ប្រព័ន្ធ E-VAT។ ដូច្នេះប្រព័ន្ធ E-VAT គឺគាត់ត្រូវតែចេះប្រើ ដោយមិនមានការលើកលែងចំពោះស្ថាប័នមួយណាឡើយ ចាប់អនុវត្តតាំងពី ខែ ៧ ឆ្នាំ២០១៩មកម្លេះ។ ដូច្នេះE-filing មានបន្ថែមរួមបញ្ចូលទាំង E-VAT ស្រាប់ ផងហើយនិងមុខងារពន្ធប្រាក់បៀវត្សរ៍ និងពន្ធកាត់ទុក។ បើសិនជាគាត់មិនទាន់ចេះប្រើ E-filing នៅមុខ ងារថ្មីនៃពន្ធកាត់ទុក ហើយប្រាក់បៀវត្ស យ៉ាងហោចណាត់គាត់ត្រូវចេះប្រើ ប្រព័ន្ធ E-filing នេះនៅមុខ ងារបញ្ជីទិញលក់ (E-VAT)។ រីឯមុខងារប្រកាសពន្ធកាត់ទុក និងប្រាក់បៀវត្សគឺគាត់អាចបំពេញដោយ ដៃបាន។

**សំណួរទី ៧**: ប្រសិនបើអង្គការបានចុះបញ្ជីរួចហើយជាបុគ្គលជាប់ពន្ធធំ។ ហើយមានសកម្មភាព អាជីវកម្មជាច់ដោយឡែក។ តើអាចចុះបញ្ជីសកម្មភាពដាច់ដោយឡែកនៅសាខាខេត្តដែលអង្គការបើក សកម្មភាពអាជីវកម្មបានដែរឬទេ? ដោយសារអង្គការមានស្នាក់ការនៅខេត្តកំពត។

**ចម្លើយ**: ជាទូទៅអង្គការ សមាគមទាំងបរទេស និងក្នុងស្រុកបានចុះបញ្ជី គឺស្វ័យប្រវត្តិចុះឈ្មោះ ជាអ្នកជាប់ពន្ធមធ្យម។ ក្នុងករណី ដែលអង្គការមានសកម្មភាពសេដ្ឋកិច្ចដោយឡែកដែលផលរបរនៃ សកម្មភាពសេដ្ឋកិច្ចទាំងឡាយនោះស្ថិតនៅក្នុងជាអ្នកជាប់ពន្ធតូចគឺតម្រូវឱ្យចុះ អ្នកជាបប់ពន្ធតូច ផល របរមធ្យម ចុះបញ្ជីជាប់ពន្ធមធ្យម បើផលរបរធំ តម្រូវជាចុះបញ្ជីជាប់ពន្ធធំ។

**សំណួរទី ៧**: ខាងអង្គការយើងខ្ញុំបានរត់ឯកសាររួចហើយ តែមិនទាន់ទទួលបានអត្តលេខនៅ ឡើយ តើអាចប្រកាសពន្ធតាមតាមប្រពន្ធ័ E-filing បានទេ?

**ចម្លើយទី៧៖** ចំពោះប្រព័ន្ធ E-filing តម្រូវឱ្យមាននៅព័ត៌មានសំខាន់បី ទី១ លេខ VATIN ទី២ លេខសម្គាល់ចុះ បញ្ជី ពន្ធដារគឺលេខកាត និងទី៣ លេខទូរស័ព្ទអ្នកឈរឈ្មោះលើប៉ាតង់។ ដូច្នេះ

ព័ត៌មានទាំងបីនេះមិនអាចអត់មួយណាបានទេ។ គឺមិនអាចចូលទៅក្នុងប្រព័ន្ធ E-Filing នេះបានទេ ប្រសិនបើគាត់កំពុងចុះបញ្ជីរ ឬធ្វើបច្ចុប្បន្នភាពមិនទាន់ជោគជ័យ។ គាត់អាចមានសំណួរបន្តទៀតថា តើការដាក់លិខិតប្រកាស់របស់គាត់យ៉ាងណាដែរ? ជាធម្មតា គាត់អាចដាក់លិខិតមក ហើយបញ្ជាក់ពីហេតុផលទៅ ហើយអាចមានជាភ័ស្តុតាងបញ្ជាក់ថាគាត់កំពុងតែចុះបញ្ជី ឬកំពុងធ្វើបច្ចុប្បន្នភាព ដូច្នេះសុំការលើកលែងឬពន្យាពេលនៃការធ្វើ E-Filingនេះ។

**សំណួរទី៨**: តើអ្វីជាបញ្ហាប្រឈមបច្ចុប្បន្នសម្រាប់អគ្គនាយកដ្ឋានពន្ធដារក្នុងការទទួលនូវការធ្វើ E-filing រវាងអ្នកជាប់ពន្ធ និងអគ្គនាយកដ្ឋានពន្ធដារ ដោយអ្នកជាប់ពន្ធតែងតែលើកឡើងថាមានការបញ្ជាក់លេខកូដ តាមE-mail តែដោយសារលេខទូរស័ព្ទ និងE-mailមានការផ្លាស់ប្តូរញឹកញាប់ព្រោះបុគ្គលិកលាឈប់ ឬផ្លាស់ប្តូរការងារបាត់?

**ចម្លើយទី៨៖** ពាក់ព័ន្ធនឹងបច្ចេទេសនេះគឺទិន្នន័យទាំងបី ដូច្នេះបើសិនជាមានការ update លើលេខទូរស័ព្ទ តម្រូវឱ្យគាត់មកធ្វើបច្ចុប្បន្នភាពជាមួយអគ្គនាយកដ្ឋានពន្ធដារនូវលេខទូរស័ព្ទថ្មីនោះ។ ឧទាហរណ៍ បុគ្គលិកចាស់ចេញ ហើយបុគ្គលិកថ្មីចូល គាត់ស្គាល់/មានគណនយ្យរបស់គាត់ ដូច្នេះគាត់មានទិន្នន័យសំខាន់ទាំងបី ជាពិសេសលេខទូរស័ព្ទដែលគាត់បានឈរលើប៉ាតង់ដែលអាចទទួលនូវសារបញ្ជាក់បាន។ករណីនេះមិនមែនជាបញ្ហាប្រឈមរបស់ពន្ធដារទេ វាជាបញ្ហារបស់ ម្ចាស់សហគ្រាសដែលគាត់ភ្លេចនូវព័ត៌មានណាមួយ។ គាត់អាចមានជម្រើសមួយ គាត់អាច Chat មក GDT LiveChat រៀងរាល់ម៉ោងធ្វើការ ឧទាហរណ៍ថា គាត់ត្រូវការធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទអ្នកឈលើប៉ាតង់មក GDT LiveChart ពេលនោះគាត់នឹងទទួលបានទម្រង់មកបំពេញដើម្បីធ្វើបច្ចុប្បន្នភាព។ អញ្ចឹងពេលធ្វើបច្ចុប្បន្នភាពរួចរាល់ គាត់នឹងទទួលបានសារSMS ទៅលេខទូរស័ព្ទថ្មីនោះ។

**សំណួរទី៩៖** តើការកែប្រែទិន្នន័យអ្វីខ្លះត្រូវការចំណាយសេវា និងការកែប្រែទិន្នន័យអ្វីខ្លះមិនចំណាយសេវាចំពោះអង្គការ/សមាគម?

**ចម្លើយ៩៖** ដូច្នេះរាល់ពេលដែលមានព័ត៌មានកែប្រែនៅក្នុងការប្រើ E-filing គឺ ត្រូវតែ ធ្វើបច្ចុប្បន្នភាព តាម GDT livechat ដើម្បីធ្វើបច្ចុប្បន្នភាព។ ចំពោះការកែប្រែព័ត៌មានប្រធាន ឬអាស័យដ្ឋាន ខាងអគ្គនាយកដ្ឋានពន្ធដារព្យាយាមធ្វើឱ្យលឿន ហើយការកែប្រែនេះមិនមានតម្រូវឱ្យបង់ប្រាក់ទេ ប៉ុន្តែសុំតែព័ត៌មាននេះគឺព័ត៌មានពិតប្រាកដហើយអ្នកទទួលខុសត្រូវច្បាស់លាស់។ព័ត៌មានមិនច្បាស់លាស់ដែលអគ្គនាយកដ្ឋានធាប់បានជួបប្រទះ ឧទាហរណ៍ ជួនកាលគាត់ដាក់អាស័យដ្ឋានចាស់



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

ហើយលេងទូរស័ព្ទទំនាក់ទំនងគឺគាត់ដាក់អ្នករត់ការ ហើយអ្នករត់ការបានឈប់បាត់ទៅខាងពន្ធដារមានការពិបាកនៅក្នុងការស្វែងរកគាត់។ ហើយចំពោះអង្គការ សមាគមដែលជួបបញ្ហាស្មុគស្មាញ អាចដាក់លិខិតមកអគ្គនាយកដ្ឋានពន្ធដារថាបានធ្វើបច្ចុប្បន្នភាពចាប់ពីថ្ងៃណាមកហើយ ហើយមានជួបបញ្ហាអ្វីខ្លះដើម្បីឱ្យអគ្គនាយកដ្ឋានពន្ធដារធ្វើការឆ្លើយតបមកវិញ។

**សំណួរទី១០:** នាងខ្ញុំសូមស្នើរដល់អគ្គនាយកដ្ឋានពន្ធដារ មេត្តាបង្កើតជាវីឌីអូពេញលេញលើការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ ដោយចែករំលែកនៅលើ Facebook page របស់អគ្គនាយកដ្ឋានដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធបានរៀនសូត្រគ្រប់ៗគ្នា។

**ចម្លើយទី១០៖** យើងខ្ញុំជាស្ថាប័នផ្តល់សេវាកម្មសាធារណៈមិនថាចំពោះអង្គការសង្គមស៊ីវិលសមាគម ខាងយើងខ្ញុំនឹងព្យាយាមផ្តល់អ្វីដែលអាចធ្វើទៅបានតាមរយៈសិក្ខាសិលា LiveChat ចំពោះសំណើរខ្ញុំនឹងទទួលយក ហើយនឹងរាយការណ៍ជូនទៅថ្នាក់ដឹកនាំ។

**សំណួរទី១១:** សម្រាប់ E-Filling តើអគ្គនាយកដ្ឋានពន្ធដារតម្រូវអោយអង្គការ/សមគមចាប់ផ្តើមអនុវត្តន៍ចាប់ពីខែណា? តើមានការលើកលែងផាក់ពិន័យដែរឬទេ បើយើមានការយឺតយ៉ាបក្នុងប្រើប្រាស់ប្រពន្ធថ្មីនេះ?

**ចម្លើយទី១១៖** E-Filling អគ្គនាយកដ្ឋានតម្រូវឱ្យអនុវត្ត គឺការប្រកាសពន្ធក្នុងខែមិថុនា រួមទាំងការដាក់វិធានការផងមានចិរវេលាចន្លោះ ពីថ្ងៃទី១ រហូតដល់ថ្ងៃទី២៥ខែកក្កដា តាមរយៈ E-Filling (ជាប់ពន្ធខែមិថុនា និងអនុវត្តប្រកាសពន្ធតាម E-Filing ចាប់ពីខែកក្កដាចាប់ពីថ្ងៃទី១ រហូតដល់ថ្ងទី២៥)។ ប៉ុន្តែបើលើសដល់ថ្ងៃទី ២៦ នឹងមានការពិន័យដូចជាច្បាប់សារពើរពន្ធ។

**សំណួរទី១២:** អង្គការសមាគមដែលមិនស្វែងរកប្រាក់ចំណេញ ជួលឡាន តែអ្នកផ្គត់ផ្គង់មិនជាប់អាករទេ តើអង្គការ/សមាគមត្រូវបង់ពន្ធដែរឬទេ?

**ចម្លើយទី១២៖** ត្រូវបង់ គឺបង់ពន្ធកាត់ទុក។

**សំណួរទី១៣:** អាចលើកជាឧទាហរណ៍ពីប្រភេទវិក្កយប័ត្រមិនអនុញ្ញាតឥណទាន។

**ចម្លើយទី១៣៖** ឧទាហរណ៍វិក្កយប័ត្រមិនអនុញ្ញាតឥណទាន ក្នុងន័យនេះមានន័យថាទៅទិញទំនិញ សេវាពីគេ គឺគេ Charge VAT ពីគាត់ ប៉ុន្តែគាត់មិនអាច Claim VAT វិញបានទេ ដូច្នេះសហគ្រាសទូទៅដូចជា មន្ទីរពេទ្យ ជាសាលារៀន អាចជាធនាគារ អាចជាធនារ៉ាប់រង និយាយជារួមគាត់ជាស

ហគ្រាសដែលផ្គត់ផ្គង់មិនជាប់អាករ។ នៅពេលដែលគាត់ជាអ្នកផ្គត់ផ្គង់មិនជាប់អាករ ទៅទិញទំនិញឬសេវាពីគេដែលជាអ្នកផ្គត់ផ្គង់ជាប់អាករ ដូច្នេះ ទោះបីជាគេកាត់ VATពីគាត់ក្តី ក៏គាត់មិនអាចតៀមទា VATពីរដ្ឋវិញបានដែរ។

**សំណួរទី១៤**: តើអង្គការចាំបាច់ត្រូវបញ្ចូលទិន្នន័យទាក់ទងនឹងការទិញលក់ដែររឺទេ?

**ចម្លើយ១៤**: នៅក្នុង E-Filling មិនបែងចែកថាអង្គការឬក្រុមទូទៅ គឺយើងតម្រូវឱ្យប្រើប្រាស់។ រាល់ពេលដែលមានវិក័យទិញត្រូវយកទៅបញ្ចូលទៅតាមប្រភេទ VATនោះ។

**សំណួរទី១៥**: តើE-Filing ធម្មតា មិនមែនជាDesktop application) អាចអាប់ឡូត(upload) ប្រតិបត្តិការចូលឬទេ?

**ចម្លើយទី១៥**: ចំពោះE-Filing នៅលើវេបសាយយើងបញ្ចូលប្រតិបត្តិការមួយៗ មិនអាចបញ្ចូលជាបាច់បានទេ។ ករណីចង់បញ្ចូលជាបាច់ គឺតម្រូវUpload ជា Excel Template តាម Desktop Applicationដែលគ្រោងដាក់ឱ្យប្រើប្រាស់នៃពេលឆាប់ៗនេះ។

**សំណួរទី១៦**: ប្រសិនបើយើងប្រាស់ E-Fillingនេះហើយ តើយើងនៅតែបន្តប្រើE-VAT ឬឈប់?

**ចម្លើយទី១៦៖** គឺយើងលែងមាន E-VAT ទៀតហើយដោយវាបង្កប់នៅក្នុង E-Filling ហើយ។

**សំណួរទី១៧**: សំរាប់បុគ្គលិកដែលមានប្រាក់ខែផ្លាស់ប្តូរពី១ខែទៅ១ខែ ឬមានប្រាក់កំរៃបន្ថែមម៉ោង តើយើងអាចចូលទៅកែប្រែព័ត៌មាននៅក្នុងខែនិមួយៗដែរឬទេ?

**ចម្លើយទី១៧៖** សម្រាប់ខែដំបូងគឺយើងត្រូវបញ្ចូលទាំងអស់ជា Manual មួយៗនៅក្នុងប្រព័ន្ធ។ នៅក្នុងការកែប្រែទិន្និន័យ ការឡើងប្រាក់ខែ គឺអាចចូលទៅកែប្រែក្នុង system បានឬបើលាឈប់អាចចូលទៅលុបឈ្មោះពី Systemបាន។

**សំណួរទី១៨**: សូមជួយបកស្រាយ លើE-Filling ម្តងទៀត ចំពោះអង្គការមិនស្វែងរកប្រាក់ចំណេញ មិនអនុញ្ញាតឥណទានអាករតម្លៃបន្ថែម តើអង្គការមិនស្វែងរកប្រាក់ចំណេញត្រូវជ្រើសអាករមិនអនុញ្ញាតឥណទាន ឬយ៉ាងណា ពេលធ្វើE-Filling?


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

**ចម្លើយទី១៨៖** មិនប្រកាន់ថាអង្គការ ឬសហគ្រាសនោះទេ និយាយឱ្យខ្លីគឺត្រូវសួរខ្លួនយើងវិញថា តើយើងអាច claim VAT បានដែររឺទេ ប្រសិនបើយើងមិនអាច claim VAT បានទេ ដូច្នេះពេលបញ្ចូល នូវបញ្ជីទិញទាំងអស់ ដែលគេ charge VAT យើងហ្នឹង គឺយើងត្រូវជ្រើសយកថាមិនអនុញ្ញាតឥណទាន។ ប្រសិនបើយើងជ្រើសយកថា VAT 10% គឺយើងត្រូវ claim VAT ពីរដ្ឋហើយ ដូច្នេះការបញ្ចូលរបស់យើងគឺមិនត្រឹមត្រូវ។

## ៤. បិទកម្មវិធី

លោក **មាស យាង** នាយកប្រតិបត្តិនៃអង្គការ (CCIM) និងជាតំណាងក្រុមការងារផ្នែកពន្ធដារ និងហិរញ្ញវត្ថុនៃអង្គការសមាគមៈ ជាដំបូងលោកសូមអរគុណដល់ អ្នកសម្របសម្រួល លោកយឿង សុធារ៉ា និងវាគ្មិនទាំងបីរូបដែលចំណាយពេលវេលា ធ្វើបទបង្ហាញដល់សិក្ខាកាមយើងទាំងអស់គ្នា។ កិច្ចការងារមួយចំនួនយើងមានការកែប្រែច្រើន ដូច្នេះខ្ញុំសូមសំណូមពរឱ្យសិក្ខាកាមយើងទាំងអស់មានការយកចិត្តទុកដាក់ តាមដានព័ត៌មានខាងផ្នែកច្បាប់ពន្ធដារ ឬច្បាប់ការងារមួយចំនួន។ ថ្មីៗនេះរដ្ឋាភិបាលបានចេញអនុក្រឹត្យមួយផាកពិន័យ ស្តីពីអន្តរការណ៍នៃគណនេយ្យ និងសវនកម្មដែលទាក់ទងនឹងអង្គការសង្គមស៊ីវិលរបស់យើងតែម្តង។ ជាចុងក្រោយសូមអរគុណដល់សិក្ខាមដែលបានអ្នកចូលរួម និងសង្ឃឹមថានឹងយកអ្វីពីចេញពីការវេទិការៀនសូត្រយកទៅអនុវត្តនៅក្នុងស្ថាប័នរបស់ខ្លួនប្រកបដោយភាពជោគជ័យ។

## ៥. លទ្ធផលវាយតម្លៃវគ្គសិក្សារៀនសូត្រ

បន្ទាប់ពីបញ្ចាប់វេទិកាសិក្សារៀនសូត្រស្តីពី លោក សុខ ណេង អ្នកសម្របសម្រួលផ្នែកសិក្សារៀនសូត្រ បានសំណូមពរឲ្យសិក្ខាកាមផ្តល់នូវព័ត៌មានត្រឡប់ដោយពិភាក្សាទៅលើប្រធានបទសម្រាប់ និងការវាយតំលៃទៅលើវេទិការទាំងមូលដោយសិក្ខាកាមតាមរយះអនឡាញ(Google Forum)។ ខាងក្រោមគឺជាលទ្ធផលលម្អិតនៃមតិយោបល់ត្រឡប់របស់សិក្ខាកាមចំនួន៤១នាក់ ក្នុងចំណោមអ្នកចូលរួមវេទិកាសរុប ២២៣នាក់:

### ៥.១.ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

តាមលទ្ធផលគឺ ពិន្ទុមធ្យមសរុបមានចំនួន ៤១ (៣៦/១០=៤) បង្ហាញថាសិក្ខាកាមពេញចិត្តខ្លាំងចំពោះប្រធានបទ និងវេទិកាសិក្សារៀនសូត្រទាំងមូល។ លទ្ធផលបានបង្ហាញថា ប្រធានបទនេះទាក់ទងនឹងការងាររបស់ខ្ញុំ ៤៩% ពេញចិត្តខ្លាំងណាស។ ហើយចំណុចវាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ ៥៩% ពេញចិត្តខ្លាំង និងគោលបំណងវេទិកាត្រូវបានបំពេញ ៤៤% ពេញចិត្តខ្លាំង។ ទោះបីជាយ៉ាងណា សិក្ខាកាមបានដាក់ពិន្ទុ ៤២% ពេញចិត្ត និង២៩% ពេញចិត្តខ្លាំងលើការបែងចែកពេលវេលាសម្រាប់វេទិកាមានរយៈពេលគ្រប់គ្រាន់ដែលមានចំនួន២៧%មិនពេញចិត្ត។ សូមមើលក្នុងតារាងទី១។

តារាងទី១៖

| តើអ្នកយល់យ៉ាងដូម្តេចចំពោះចំណុចខាងក្រោម?សូមដាក់ពិន្ទុពី ១ ដល់ 5<br>១ = មិនពេញចិត្តសោះ ៥ = ពេញចិត្តខ្លាំងណាស់ | ១<br>% | ២<br>% | ៣<br>% | ៤<br>% | ៥<br>% | សរុប<br>% | ពិន្ទុមធ្យម |
|---|---|---|---|---|---|---|---|
| ១.ការលើកទឹកចិត្តឲ្យមានសកម្មភាពចូលរួម | 0 | ៥ | ៣៧ | ៤៦ | ១២ | ១០០ | ៤ |
| ២.ប្រធានបទនេះទាក់ទងនឹងការងាររបស់ខ្ញុំ | 0 | ៧ | ១៥ | ២៩ | ៤៩ | ១០០ | ៤ |
| ៣.មាតិកាត្រូវបានរៀបចំយ៉ាងល្អ ហើយងាយយល់ | 0 | ១៥ | ៣៩ | ៤២ | ៥ | ១០០ | ៣ |
| ៤.សម្ភារៈ/ឯកសារដែលបានផ្តល់ឲ្យមានសារៈប្រយោជន៍មែនទែន | 0 | ១២ | ៣២ | ៣៤ | ២២ | ១០០ | ៤ |
| ៥.ការចែកចាយបទពិសោធន៍ក្នុងវេទិកានេះ នឹងមានសារៈប្រយោជន៍ជាខ្លាំងសម្រាប់ការងាររបស់ខ្ញុំ | ២ | ៥ | ៣២ | ៣៤ | ២៧ | ១០០ | ៤ |
| ៦.វាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ | 0 | ៥ | ២២ | ៥៩ | ១៥ | ១០០ | ៤ |
| ៧.វាគ្មិន/អ្នកសម្របសម្រួលមានការត្រៀមរៀបចំយ៉ាងល្អ | 0 | ១០ | ៣៤ | ៤៤ | ១២ | ១០០ | ៤ |
| ៨.គោលបំណងវេទិកាត្រូវបានបំពេញ | 0 | ១០ | ៣៩ | ៤៤ | ៧ | ១០០ | ៣ |
| ៩.ការបែងចែកពេលវេលាសម្រាប់វេទិកាមានរយៈពេលគ្រប់គ្រាន់ | 0 | ២៧ | ៤២ | ២៩ | ២ | ១០០ | ៣ |
| ១0.ការវាយតម្លៃជារួមទៅលើវេទិកានេះ | 0 | ៧ | ៤២ | ៤៩ | ២ | ១០០ | ៣ |
| ពិន្ទុមធ្យមសរុប | | | | | | | 36/10=៤ |

## ៦. ឧបសម្ព័ន្ធ

១. ទូផលវាយតម្លៃវគ្គសិក្សារៀនសូត្រទាំងមូល

២. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៩:២០-០៩:៣០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គសក |
| ០៩:៣០-០៩:៤០ | កិច្ចស្វាគមន៍ និងគោលបំណងវេទិការៀនសូត្រ<br>មតិស្វាគមន៍ពី លោក **សឿង សារឿន** នាយកប្រតិបត្តិ អង្គការ គសក | **លោក សុខ ណេង**<br>អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ អង្គការ គសក |
| ០៩:៤០-០៩:៥០ | ការណែនាំពីរបៀបប្រើ Google Meet និងបទបញ្ជាផ្ទៃក្នុងវគ្គ | |
| ០៩:៥០-១០:២០ | ការធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីច្បាប់ពន្ធដារ និងបទបញ្ញាតិនានាពាក់ព័ន្ធនឹងវិស័យពន្ធដារ | **លោក យឿង សុធារ៉ា** ប្រធានផ្នែកកសាងភាពជាដៃគូ បណ្តាញ និង ការតស៊ូមតិ នៃអង្គការ គសក |
| ១០:២០-១០:៥០ | បទបង្ហាញពីការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (E-Filing) | **វាគ្មិន៖**<br>• **លោក ប៉ូ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យមនៃអគ្គនាយកដ្ឋានពន្ធដារ (GDT)<br>• **លោក យឿន វិសាល** អនុប្រធានការិយាល័យអ្នកជាប់ពន្ធតូត និង មធ្យម<br>• **លោក ស្រេង រតនា** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ |
| ១០:៥០-១១:២០ | វេទិកាពិភាក្សា និងសំណួរចម្លើយ | |
| ១១:២០-១១: ៣០ | បូកសរុប និងបិទកម្មវិធី | **លោក មាស ឃាង** នាយកប្រតិបត្តិនៃអង្គការ (CCIM) និងជាតំណាងក្រុម |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

| | | |
|---|---|---|
| | | ការងារផ្នែកពន្ធដារ និងហិរញ្ញវត្ថុនៃអង្គការសមាគម |

៣. រូបថតវេទិការៀនសូត្រសូ

